# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI00148**

## សម្ភាសន៍ជាមួយឈ្មោះ ភឿ ជុន ភេទស្រី អាយុ៥៥ឆ្នាំ
## មុខងារនៅសម័យខ្មែរក្រហមៈ "ប្រជាជនធ្វើការកងចល័ត"
## សព្វថ្ងៃរស់នៅភូមិដើមវត្ត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ សោម ប៊ុនថន និង ចាន់ ប្រុញ
## ០០:៥៤:៤៥
## ៣០ទំព័រ

ប៊ុនថន ៖ អ៊ីចឹងជំបូងខ្ញុំសួរឈ្មោះអ្នកមីង អ្នកមីងឈ្មោះអីដែរ?

ជុន ៖ ខ្ញុំឈ្មោះ នាមត្រកូល ភឿ ជុន ។

ប៊ុនថន ៖ ភឿ ជុន ។ សព្វថ្ងៃអាយុប៉ុន្មានឆ្នាំ?

ជុន ៖ អាយុ៥៥ឆ្នាំ ។

ប៊ុនថន ៖ មីង! ស្រុកកកំណើតនៅភូមិឃុំអីដែរ?

ជុន ៖ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យនេះឯង ។

ប៊ុនថន ៖ ភូមិ?

ជុន ៖ ដើមវត្ត ចា៎!

ប៊ុនថន ៖ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ?

ជុន ៖ ចា៎!

ប៊ុនថន ៖ មីងមានបងប្អូនប៉ុន្មាននាក់?

ជុន ៖ ស្រីបីប្រុសពីរ ។

ប៊ុនថន ៖ មីងកូនទីប៉ុន្មាន?

ជុន ៖ ខ្ញុំកូនទី៣ ។

ប៊ុនថន ៖ បងប្អូននៅរស់ទាំងអស់?

ជុន ៖ ស្លាប់សម័យបដិវត្តន៍ បងស្រីទីពីរ ។

ប៊ុនថន ៖ គាត់ស្លាប់ដោយសារអីដែរ?

ជុន ៖ ស្លាប់សម័យបដិវត្តន៍ ដោយគាត់អត់បាយ ។ គាត់ពិសារតែបបរ ក៏ដូចជាក្នុងម៉ាខ្ទះដាក់តែចំនួនពីរកំប៉ុង គាត់អត់ចេះពិសារទេ ។ បន្ទែគាត់អត់ចេះពិសារទេ ក៏ចេះតែនេះទៅ ក៏ឃើញដាច់ពោះស្លាប់ទៅណា ។

ប៊ុនថន ៖ ស្លាប់ឆ្នាំណាដែរ? មីងមានចាំទេ!

ជុន ៖ ៧៦-៧៧ ។

ប៊ុនថន ៖ ស្លាប់នៅណាមីង?

ជុន ៖ ស្លាប់! កាលនៅសម័យ ប៉ុល ពត ចល័តទៅនៅភូមិតាប៉ែន ។

ប៊ុនថន ៖ ស្លាប់នៅតាប៉ែន?

ជុន ៖ ចាំ! គេចល័តទៅនៅតាប៉ែនហ្នឹងឯង ។

ប៊ុនថន ៖ អ្នកមីង! ឪពុកម្ដាយអ្នកមីងនៅរស់ទេសព្វថ្ងៃនេះ?

ជុន ៖ នៅរស់ ប៉ុនគាត់វង្វេងហើយសព្វថ្ងៃនេះ ។

ប៊ុនថន ៖ គាត់អាយុប៉ុន្មាន?

ជុន ៖ អាយុ៨២ ។

ប៊ុនថន ៖ នៅទាំងពីរ?

ជុន ៖ ទេ! ឪពុកស្លាប់តាំងពីខ្ញុំអាយុ១៣ឆ្នាំ ។

ប៊ុនថន ៖ ស្លាប់ជំនាន់ណាដែរមីង? ជំនាន់សម្ដេច ឬ លន់ នល់ ។

ជុន ៖ ទេ! ជំនាន់មិនទាន់ លន់ នល់ ទេ ។ មិនដឹងជំនាន់ស្អី ។

ប៊ុនថន ៖ សម្ដេចអីទេ?

ជុន ៖ ចាំ!

ប៊ុនថន ៖ ជំនាន់៦០ជាង?

ជុន ៖ ចាំ!

ប៊ុនថន ៖ សម័យ៦០ជាង?

ជុន ៖ មុនសម័យ លន់ នល់ ។ លន់ នល់ ខ្ញុំធំហើយ ។

ប៊ុនថន ៖ អ៊ីចឹងអ្នកមីងរៀនសូត្រដល់ណាដែរកាលពីក្មេង?

ជុន ៖ ខ្ញុំនៅកំព្រាអត់បានរៀន ។ ខ្ញុំបានរៀនត្រឹមថ្នាក់ទី១០ចាស់ ប្រហែលសព្វថ្ងៃថ្នាក់ទី៣ ។

ប៊ុនថន ៖ ប៉ុន្តែអាចអានបានទេ?

ជុន ៖ អានបាន ។

ប៊ុនថន ៖ ក្រោយមកមានរៀនបន្ថែមទៀតទេ?

ជុន ៖ អត់ៗ មើលប្អូន ដែលឪពុកស្លាប់ទៅ ប្អូនអាពៅគេវាទើបបានមួយខួបជាង ក៏មើលប្អូនៗ ផុតពីមើលប្អូនម៉ែទៅច្រូតទៅ ក៏មើលគោៗ បើបងៗគេបានរៀនខ្លះ ប្អូនក្រោយបានរៀន ខ្ញុំត្រឹមទីបីមើលគោ ភ្ជួរស្រែ ទៅរាស់ស្រែជាមួយបងៗ

ប៊ុនថន ៖ កាលនោះរៀននៅសាលាណាអ្នកមីង?

ជុន ៖ សាលាយើងនៅនេះឯងៗ សាលារៀនព្រះនេត្រព្រះពីដើមៗ

ប៊ុនថន ៖ បឋមសិក្សាកាលនោះ?

ជុន ៖ ចា៎!

ប៊ុនថន ៖ កាលនោះសិស្សរៀនច្រើនទេ?

ជុន ៖ ច្រើន សាលារៀននោះច្រើនៗ

ប៊ុនថន ៖ ចោះនៅក្នុងភូមិនេះ ក្មេងច្រើនទេជំនាន់នោះ?

ជុន ៖ ជំនាន់ខ្ញុំ!

ប៊ុនថន ៖ បាទ?

ជុន ៖ ច្រើនៗ គេអ្នកមាន ដូចថាម៉ែឪគេមិនទីទល់ក៏បានរៀនទៅ ដល់ថ្នាក់ទីមួយទីពីរៗ

ប្រុញ ៖ ទីមួយទីពីរជំនាន់មុន?

ជុន ៖ ចា៎! នុះហើយហើយ ដូចជាយើងរាប់ថ្នាក់ទី១២ៗ

ប៊ុនថន ៖ ចោះមីងបានចូលកងទេជំនាន់មុន?

ជុន ៖ មានតើៗ

ប៊ុនថន ៖ មានដូលកងដែរ?

ជុន ៖ មាន ចូលកង វ៉ាកងអីមានៗ ចូលកង ពេលវ៉ាកងបាយវេច ជប់លៀងនៅសាលាដូច សព្វថ្ងៃៗ

ប៊ុនថន ៖ ចូលកង! ចូលបដិវត្តន៍អ្នកមីង?

ជុន ៖ អ្ហូ! ចូលបដិវត្តន៍ៗ

ប៊ុនថន ៖ មានទេអ្នកមីង?

ជុន ៖ បដិវត្តន៍ មានចូលកងឯណាៗ

ប៊ុនថន ៖ ចូលបដិវត្តន៍ជាមួយខ្មែរក្រហម?

ជុន ៖ អ្ហូ! មិនមានឯណា ដូចថាយើងតូចចល័តអ៊ីចឹងគេប្រើទៅម្តុំ ។ យើងអ្នកស្លូតអ៊ីចឹងទៅ មិនមែនអ្នកដាច់ខាត បើអ្នកដាច់ខាតទៅនៅមួយឡែក ។ អ្នកដែលទៅពីភូមិទៅធ្វើទំនប់ អ៊ីចឹងទៅ ទៅនៅមួយឡែក ។

ប្រុញ ៖ ដាច់ខាត ។ ដាច់ម៉េចវិញ?

ជុន ៖ ដាច់! ដូចថាបម្រើជំនាន់ ដូចថាបម្រើជំនាន់និរតី ឬសេនាជនអ៊ីចឹងទៅ ។ ដាច់ខាត់ទៅ បម្រើនៅក្រុមជុំគេទៅ ។

ប៊ុនថន ៖ អ៊ីចឹងមីងនៅសម័យ លន់ នល់ ហើយ មីងនៅភូមិឃុំដដែល?

ជុន ៖ នៅតាដែល ។

ប៊ុនថន ៖ អ៊ីចឹងអត់មានខ្មែរក្រហមអីចូលមកដល់នេះទេ?

ជុន ៖ ទេ ។ សម័យនោះ មិនមានខ្មែរក្រហមនៅឈរជើងនេះទេ ។ បើវាចូលមក ដូចថា វាចូល មកអុកឡុកអី យប់វាចូលមកលួចឆ្មក់ បាញ់បង្អើលអីមាន ។ ថាត្រង់មកឈរជើងនៅនេះ អត់មានទេ ។

ប៊ុនថន ៖ ប៉ុន្តែដែលមកចូលឃោសនានៅក្នុងភូមិទេ?

ជុន ៖ អត់ ។

ប៊ុនថន ៖ អត់ដែលទេ?

ជុន ៖ អត់ដែលទេ ។

ប៊ុនថន ៖ ចោះបាញ់អី មានរបួសមានអីទេអ្នកមីង?

ជុន ៖ របួស ស្លាប់ មានតាមនេះឯង ។

ប៊ុនថន ៖ ពីណាបើតាមមីងដឹង?

ជុន ៖ ស្លាប់ខាង ប៉ុល ពត នេះឯង ។ យើងនេះបាញ់ទៅ អីនុះបាញ់មក អីនេះផ្លោងទៅក៏ បានស្លាប់នៅកន្លែងស្រះត្រង់ណោះ ។ វាលូន ។

ប៊ុនថន ៖ គេចូលមកធ្វើអីមីង? ខ្មែរក្រហមចូលមក ។

ជុន ៖ ទេចូលមក ដឹងចូលមកចង់ធ្វើអី ។ ហ្វូងទាហានឈរនៅត្រង់ប៉ុស្តិ៍ប៉ូលីសត្រង់នេះឯង ។

ប៊ុនថន ៖ ជិតវត្ត?

ជុន ៖ ប៉ូលីសពីដើមម៉ិញនៅកន្លែងផ្សារ ។ ប៉ុស្តិ៍ទាហានចាំ ។

ប៊ុនថន ៖ អ៊ីចឹងបានជាគេដាក់ប៉ុស្តិ៍ចាស់?

ជុន ៖ ចាំ!

ប៊ុនថន ៖ អ៊ីចឹងខ្មែរក្រហមអត់មានចូលមកយូរទេ?

ជុន ៖ អត់មានដែលបានចូលមកនៅ ឈរនៅយូរទេ។ គ្រាន់ថាដូចឆ្នាំ យប់ឬក៏ស្អីតែប៉ុណ្ណោះ ៦៨។

ប្រុញ ៖ ចោះដល់ពេលចូលមកគេជម្លៀសទៅណាដែរទេ?

ជុន ៖ ខ្មែរក្រហមដែលចូលមកនៅឈរជើងនៅជ្រោយតាប៉ែន!

ប៊ុនថន ៖ បាទ?

ជុន ៖ ជម្លៀសទៅនៅភូមិតាប៉ែន។

ប៊ុនថន ៖ ទៅទាំងអស់គ្នា?

ជុន ៖ ទៅទាំងអស់គ្នា។ ម៉ាភូមិជើងវត្តនេះនៅភូមិតាប៉ែន។

ប៊ុនថន ៖ ម៉ាភូមិទេ ឬក៏មានភូមិផ្សេងទៀតទៅនៅភូមិតាប៉ែនដែរ?

ជុន ៖ មានភូមិដូចថា កាលនោះគេសរសេរឈ្មោះ ដូចថាលើសពីក្នុងក្រុម ប៉ុន្មានក្រុមហ្នឹងមាន ចម្រុះគ្នាទៅ បើសល់ពីកន្លែងចម្រុះយកទៅដាក់លាយខ្វះទៅ។ ហើយខាងទីក្រុងភ្នំពេញមក នៅហ្នឹងតាប៉ែន ដូចហៅថាជាប្រជាជនថ្មី។

ប៊ុនថន ៖ អ៊ីចឹងនៅលាយគ្នាជាមួយអ្នកចាស់ហ្នឹង?

ជុន ៖ ចា៎! អ្នកចាស់អ្នកថ្មីលាយគ្នាទាំងអស់។

ប៊ុនថន ៖ ទៅដល់គេបែងចែកយ៉ាងម៉េចដែរអ្នកមីង?

ជុន ៖ បែងចែកជាក្រុម ជាកង។ មួយក្រុម មាន១០នាក់។ មួយកង មាន៣០គ្រួសារ។ ក្នុងមួយក្រុមមាន១០គ្រួសារ សម្រាប់ដូចថាយើងដោះស្រាយ ដូចថាគេបើកអង្ករបើកអីឲ្យទៅ ក្នុងមួយក្រុមដូចគេថែថា ដូចថាអង្ករចំនួនមួយតៅអ៊ីចឹងយើងវាល់ចែកគ្នា។

ប៊ុនថន ៖ អ៊ីចឹងអត់គិតមនុស្សម្នាក់ទេ។ គិតមួយគ្រួសារ?

ជុន ៖ មួយគ្រួសារ។ ដូចថាមួយគ្រួសារ មានគ្រួសារតិច កូនច្រើន។ បីនាក់គេថែតាមបីនាក់។ ប្រាំពីរនាក់ ឬក៏ដប់នាក់ចែកតាមនោះហើយ។ ក្នុងម្នាក់បាន៣កំប៉ុង អ្នក១០នាក់ក៏បាន៣០កំប៉ុង។

ប៊ុនថន ៖ អ៊ីចឹងមីងបានចូលកងដែរ?

ជុន ៖ ខ្ញុំ!

ប៊ុនថន ៖ បាទ?

ជុន ៖ កងចល័តជានារីភូមិ។

ប៊ុនថន ៖ កងចល័តនារី?

ជុន ៖ នារីភូមិ ។

ប៊ុនថន ៖ មួយកងមីងប៉ុន្មាននាក់?

ជុន ៖ មួយកងសាមសិបនាក់ ។

ប៊ុនថន ៖ កងតូច?

ជុន ៖ កងតូច ។

ប៊ុនថន ៖ អ្នកមីងនៅជាមួយអ្នកណា? អ្នកណាប្រធានកង ។

ជុន ៖ សព្វថ្ងៃដឹងគេទៅណាអស់ហើយ ។ សម័យនេះគេជម្លៀសមកពីភូមិស៊ីងកំបុត គេមកឈរជើងនៅឃុំកូនដំរី ដល់នេះគេបំបែកឲ្យមកកាន់ក្តាប់យើងលើកទំនប់ ។

ប៊ុនថន ៖ គាត់ឈ្មោះអីមេកង?

ជុន ៖ មេកង!

ប្រុញ ៖ ឈ្មោះអីគេមេកង?

ជុន ៖ ភ្លេចឈ្មោះគេហើយ ។ ឈ្មោះគេសម័យបដិវត្តន៍ ដឹងឈ្មោះគេស្អី ឈ្មោះសព្វថ្ងៃដឹងឈ្មោះស្អីគេទេ ។ ប៉ុនឈ្មោះ ម៉ី មួយឈ្មោះ វង់ មួយចា៎ ។

ប៊ុនថន ៖ ឈ្មោះ វង់ មួយ ម៉ី មួយ?

ជុន ៖ ចា៎! ប៉ុនមិនដឹងគេទៅនៅណាទេសព្វថ្ងៃនេះ ។

ប៊ុនថន ៖ អីចឹងមិនមែនអ្នកនៅភូមិហ្នឹងទេមកពីភូមិផ្សេង?

ជុន ៖ ចា៎! អត់មានទេ មកពីភូមិផ្សេងមកកាន់ក្តាប់យើង ។ ចាត់ចែងប្រើឲ្យយើងធ្វើការងារ ។

ប្រុញ ៖ កាលជំនាន់នោះមីងធ្វើការអីគេ?

ជុន ៖ ធ្វើការជីកទំនប់ជីកអី ។ មិនដែលបាននៅភូមិទេ ។ មួយខែកន្លះខែបានមកភូមិម្តង មកលេងម៉ែម្តង ។ មកលេងមិនដែលបានយូរ ដល់គេត្រូវរើសអ្នកទៅធ្វើការទៅជីកទំនប់ទៅជីកអីទៀត ចេញទៅទៀត ។

ប្រុញ ៖ ទៅជីកនៅតាប៉ែនហ្នឹង?

ជុន ៖ អ្ហ៎! ទៅជីកទំនប់កំបោរស្រែះនេះ សុទ្ធតែកម្លាំង ។

ប៊ុនថន ៖ ចេញដំបូងទៅណាវិញមីង?

ជុន ៖ ចេញដំបូងទៅខាងគរបីដើមដូចខ្ញុំនិយាយអំមិញ ។

ប៊ុនថន ៖ បច្ចុប្បន្ននៅភូមិអីដែរមីងគរបីដើម?

ជុន ៖ គរបីដើមមិនមែនភូមិទេ គឺជាថ្នល់ជាតិ ។ ថ្នល់ចេញពីព្រៃមាន់ទៅរកភ្នំស្រុកពាក់កណ្ដាល ។

ប៊ុនថន ៖ ប៉ុនបច្ចុប្បន្នក្នុងភូមិទីតាំងក្នុងភូមិអីដែរមីង?

ជុន ៖ អត់មានភូមិទេ ។

ប៊ុនថន ៖ ចោះនៅក្នុងឃុំអីដែរ?

ជុន ៖ ភ្នំស្រុក ។

ប៊ុនថន ៖ រាល់ថ្ងៃគរបីដើម?

ជុន ៖ ខ្ញុំមិនដែលបានទៅទៀតទេ ។

ប៊ុនថន ៖ ប៉ុន្តែដឹងតែនៅភ្នំស្រុក?

ជុន ៖ ចា៎! ផ្លូវទៅភ្នំស្រុកនេះឯង ។

ប៊ុនថន ៖ ទៅច្រើនទេមីងលើកទំនប់នៅគរបីដើម?

ជុន ៖ ទៅច្រើន ។ មិនមែនទៅតែភូមិយើងនេះណា ទៅចល័តម៉ាតំបន់ប្រាំនេះមិនដឹង វាច្រើនដែរ ទំនប់ធំដឹងណា៎ ។

ប្រុញ ៖ គេហៅទំនប់អីគេ?

ជុន ៖ ទំនប់ទៅស្ពានថ្ម ។ ស្ពាច់ គិតទៅទំនប់តាមយើងអាទំនប់តាពាន់ គេនេះពីព្រៃមាន់ទៅ ។ លើកអាទំនប់នេះទៅ វៃក្រឡាឈើត្រង់តាមស្រែតាមអី ចេះតែប្រើយើងទៅណា៎ ។

ប្រុញ ៖ ទៅធ្វើនៅនោះយូរទេ?

ជុន ៖ ធ្វើនៅនោះយូរតើ ។

ប្រុញ ៖ ប្រហែលប៉ុន្មានខែដែរ?

ជុន ៖ កាលនោះមិនបានជាយកចិត្តទុកថាប៉ុន្មានខែៗទេ ។

ប្រុញ ៖ គាត់ចេញពីគរបីដើមមកបានទៅធ្វើ?

ជុន ៖ ខាងនេះ ។

ប្រុញ ៖ គេហៅអីគេ?

ជុន ៖ ទំនប់កំបោរស្រែះ ។

ប្រុញ ៖ កំប៉ោរស្រែះ?

ជុន ៖ កំបោរស្រែះ ភ្នំកំបោរ ។

ប្រុញ ៖ កំបោរស្រែះ?

ជុន ៖ ភ្នំកំបោរ មកទល់ស្រែះ ។ ពីស្រែះមក ឡើងមកដល់ប៉ុស្តិ៍ចាស់ ។

ប៊ុនថន ៖ គេភ្ជាប់តមក?

ជុន ៖ បាទ!

ប្រុញ ៖ ធ្វើនៅកំបោរស្រែះប៉ុន្មានដែរមីង?

ជុន ៖ អង្កាល់ហ្នឹងមិនបានដាយកចិត្តទុកដាក់ប៉ុន្មានខែ ។ ខ្ញុំមិនបានយកចិត្តទុកដាក់ទេ ប៉ុន្តែដឹងថាពីកំបោរមកដល់ស្រែះចប់បានគេនេះម្តង ។

ប្រុញ ៖ ធ្វើដល់ចប់?

ជុន ៖ បាទ! ចប់ ។ ចប់ហើយគេលេងសិល្បៈ ដូចថាយើងគេសម្ពោធអីនេះទៅ ។ បានឡើងពីស្រែះអីទៅមកនេះវិញ មកភូមិវិញ ។

ប៊ុនថន ៖ ចាកមកភូមិវិញ?

ជុន ៖ ចា៎!

ប្រុញ ៖ ដល់ពេលធ្វើអាហ្នឹងចប់គេឲ្យធ្វើនៅត្រពាំងទៀត ឬអត់ទេ?

ជុន ៖ លែគេខាងត្រពាំងថ្ម គេទៅៗ ប៉ុន្តខ្ញុំអត់បានទៅ ។

ប្រុញ ៖ អត់បានទៅទេ?

ជុន ៖ អត់បានទៅទេ មុខងាររយើងអីនេះ ។ ជួនកាលខ្ញុំឈឺទៅ ឲ្យមកនៅភូមិ ជីករងដំឡូងទៅ ។

ប្រុញ ៖ អ្នកមីងដឹងរឿងគេធ្វើនៅត្រពាំងថ្ម ត្រពាំងអីខ្លះទេ?

ជុន ៖ មិនដែលដឹង ។ ដឹងមិនពិតប្រាកដ មិនដឹងថាដែលធ្វើអី ។

ប្រុញ ៖ ចោះកាលលើកទំនប់កំបោរស្រែះពីណាគេអ្នកគ្រប់គ្រងទាំងមូលនៅហ្នឹង?

ជុន ៖ តាវ៉ាល់, តាម៉ោង ។

ប្រុញ ៖ តាវ៉ាល់, តាម៉ោង?

ជុន ៖ ហ្នឹងហើយ ។ គាត់អ្នករ៉ាប់ប្លូរ ។

ប្រុញ ៖ តាវ៉ាល់, តាម៉ោង គាត់មានឋានៈអីគេមីង?

ជុន ៖ ឋានៈស្អីគេ មិនដឹងជាស្អី ។ អ្នកធំណា៎ អ្នកក្តាប់ក្តោបដូចម៉ាតំបន់ ម៉ាតំបន់៥នេះដែលគាត់លើក ក្តោបក្តាប់អ្នកលើកទំនប់ ជីកប្រឡាយ ។

ប៊ុនថន ៖ គាត់ប្រធានកងចល័តតំបន់អីចឹង?

ជុន ៖ ចា៎! តំបន់ ។

ប្រុញ ៖ ធ្លាប់ឃើញគាត់ដែរ?

ជុន ៖ គាត់មកឈរនៅនេះឯង ដើរមើលយើង ។ កូនក្មេងធ្វើអី កុមារធ្វើអីគាត់ចាត់ចែងទៅ ។

ប៊ុនថន ៖ កាលមីងទៅកំបោរស្រេះ មីងទៅនៅជាមួយប្រធានកងឈ្មោះ ម៉ី ដដែល?

ជុន ៖ ចា៎!

ប៊ុនថន ៖ គាត់ដឹងនាំរហូត?

ជុន ៖ ចា៎!

ប៊ុនថន ៖ ទៅនោះអ្នកមីងលើកទំនប់ធំទេ?

ជុន ៖ ទំនប់ធំតើ ។ ខ្នងលើបីម៉ែត្រ ខាងក្រោមប្រាំម៉ែត្រ ។

ប៊ុនថន ៖ បាទលើកបីម៉ែត្រ ។ ចុះបណ្តោយទៅចឹងដឹងប៉ុន្មាន?

ជុន ៖ មិនដឹងប៉ុន្មានគីឡូដែរ ខ្ញុំភ្លេចហើយកាលនោះ ។

ប៊ុនថន ៖ ឆ្ងាយទេ?

ជុន ៖ កំបោរស្រេះឆ្ងាយណាស់កូន ។

ប៊ុនថន ៖ អ៊្ហូនៅពោធិ៍បីដើម?

ជុន ៖ គបីដើម ។

ប៊ុនថន ៖ បាទ! គបីដើម?

ជុន ៖ គបីដើម ។

ប្រុញ ៖ ដើមគ?

ជុន ៖ បាទ! គរឈេនៅខាងលិចថ្នល់ ផ្លូវទៅភ្នំស្រុក ។ ហៅថាគបីដើមៗ អ្នកស្រុកហ្នុងហៅ ។

ប៊ុនថន ៖ ធំទេអ្នកមីងទំនប់នោះ?

ជុន ៖ ទំនប់ភ្ជោះ មិនមែនជាធំទេទំនប់ភ្ជោះ សម្រាប់ចាកប្រព័ន្ធស្រែ ។

ប៊ុនថន ៖ អ៊្ហូបង្ហូតទឹកអីទៅ?

ជុន ៖ ចា៎! បង្ហូរទឹកចេញចូល ។

ប៊ុនថន ៖ ចុះអ្នកទៅ មានអ្នកថ្មីៗទៅទេ ដូចជាមីង និងអ្នកភ្នំពេញអ្នកអីនោះ?

ជុន ៖ ទៅចម្រុះគ្នា ទៅទាំងអស់គ្នា ។

ប៊ុនថន ៖ ចុះអ្នកហ្នឹងដូចថាការងារម៉េចដែរ ធ្វើសកម្មទេមីង?

ជុន ៖ ធ្វើដូចជាថា យើងអ្នកចាស់អ្នកថ្មីអីក៏ដោយ ត្រូវគ្នា ដូចតែគ្នាទាំងអស់ហ្នឹងហើយធ្វើការហ្នឹងចា៎ ។

ប៊ុនថន ៖ ប៉ុន្តែអ្នកខ្លះដូចអត់ធ្លាប់ធ្វើអីចឹង?

ជុន ៖ អ្នកអត់ធ្លាប់ធ្វើ គ្នាធ្វើរៀងនេះដែរ ។ ប៉ុន្តែមិនហ៊ានថាខ្ជិលច្រអូសអីទេ ធ្វើតែទាំងអស់ ។

ប៊ុនថន ៈ បាទ! ប៉ុននៅនោះគេកំណត់ឲ្យធ្វើមួយថ្ងៃប៉ុន្មានដែរគបីដើម?

ជុន ៈ គបីដើម!

ប៊ុនថន ៈ បាទ?

ជុន ៈ អ្ហឺ! កាលនោះមិនដឹងជាប៉ុន្មានម៉ែត្រទេ មិនដឹងម្នាក់ប៉ុន្មានម៉ែត្របានឲ្យហូបបាយ ។ វា ភ្លេច ខ្ញុំវាភ្លេច ។

ប៊ុនថន ៈ មានដាក់ផែនការ ។ មានដាក់ផែនការទេមីង ដូចថាម្នាក់ប៉ុន្មានម៉ែត្រៗ?

ជុន ៈ ដាក់ ។ ធ្វើមានកំណត់ ព្រោះដកស្ទោមក យកមករៀបធ្វើក្នុងទឹក ។ ដកស្ទោមក យកមករៀប បានកាយផុកមកដាក់តំរៀបទៅ ។ ដឹងថាតំរៀបបានហើយ ស្ទោដាក់មួយជាន់ទៀត ធ្វើតាមក្រឡាថ្នល់អញ្ចេះ ។

ប៊ុនថន ៈ ដាំស្ទោកុំឲ្យបាក់ប្រាំង ឬមួយយ៉ាងម៉េច?

ជុន ៈ ដាំស្ទោ រៀបស្ទោហើយបានកើបដីដាក់ពីលើ ។ បើដាក់តែដី ទឹករលកមកច្រោះអស់ អត់ជាប់ជាទំនប់ទេ ។

ប៊ុនថន ៈ អ្នកភ្នំពេញ ដូចថាអ្នកធ្វើការអត់ហើយអ៊ីចឹង ដូចមីងនិយាយអំបាញ់មិញមានអ្នកខ្លះរៀង យឺតរៀងអ៊ីចឹង ។ ហ្នឹងម៉េចទៅដូចថាមានហៅណែនាំ ឬហៅអីទេមីង ដាក់ផែនការម៉េច?

ជុន ៈ ធ្វើមិនហើយបន្ថយរបប ។

ប៊ុនថន ៈ អត់ឲ្យហូប?

ជុន ៈ បន្ថយរបបបាយ ។ ធ្វើមិនហើយបន្ថយរបបបាយ កាលណាធ្វើហើយបានឈប់ ។ ម៉ា យើងផែនការបានបាយពេញ ។

ប៊ុនថន ៈ ចោះមានច្រើនទេដែលធ្វើអត់ហើយបន្ថយរបបហ្នឹង?

ជុន ៈ ធ្វើមិនហើយបន្ថយរបបមានច្រើន

ប្រុញ ៈ កាលទៅធ្វើនៅហ្នឹងមានស្លាប់ច្រើនទេ?

ជុន ៈ ស្លាប់ៗនឹងជំងឺមិនសូវមានទេ ។

ប្រុញ ៈ ស្លាប់ដោយសារជំងឺ?

ជុន ៈ ស្លាប់ដោយសារតែដាច់ពោះចាំ ។ ខ្ញុំ ម៉ែខ្ញុំផ្ញើនំទៅពីផ្ទះ សុទ្ធតែនំធ្វើពីកន្ទក់លាយត្នោត ។ កន្ទក់ អាកន្ទក់គេបែកក៏យកទៅ ។

ប៊ុនថន ៈ ផ្ញើឲ្យអ៊ីចឹងខាងនោះគេអត់ថាអីទេយើងយកទៅហូបអ៊ីចឹង?

ជុន ៖ អត់ទេ មានគ្នាដូចថាណាមិនស្រួលសុំមកផ្ទះ។ ពីរបីថ្ងៃទៅវិញ លួចលាក់ផ្ញើទៅ។ ចាំ! វេចស្ពាយទៅ ឲ្យស្ងាត់មិនឲ្យគេដឹង តែឲ្យអង្គការដឹងភ័យខ្លួន។

ប្រុញ ៖ អ្នកមីងនិយាយអំបាញ់មិញបើសិនជាគាត់ធ្វើការហើយគាត់ធ្វើបាន អ្វីហូបបានពេញអីដូចគេទាំងអស់?

ជុន ៖ ពេញរបប។

ប្រុញ ៖ ហេតុអីបានគាត់នៅដាច់បាយ ដាច់ពោះ?

ជុន ៖ ខាងគេនេះ ខាងនៅភូមិនេះអត់បានបាយហូបទេ។ អ្នកដើរតាមមុខព្រួញបានៗបាយ។ នៅតាមភូមិ ម៉ែខ្ញុំនៅតាមភូមិវាលក់ន្ទក់បែក។

ប្រុញ ៖ អ៊ីចឹងអ្នកធ្វើការនៅទីនោះបានហូបគ្រប់គ្រាន់?

ជុន ៖ បានបាយ។

ប្រុញ ៖ អ៊ីចឹងអ្នកធ្វើការនៅទីនោះបានហូបគ្រប់គ្រាន់ ប៉ុន្តែអ្នកស្លាប់ដាច់ពោះដោយសារគាត់នៅតាមភូមិ?

ជុន ៖ ចាំ!

ប៊ុនថន ៖ របបនៅនោះរបបយ៉ាងម៉េចដែរអ្នកមីងដូចថាគេបែងចែក?

ជុន ៖ បាយវាល់ ម្នាក់បីវែក។

ប៊ុនថន ៖ បីវែក?

ជុន ៖ បីវែក អាវែកដងយើង។

ប៊ុនថន ៖ ចុះដូចមីងចឹង មួយពេលបីវែកហូបគ្រប់ទេ?

ជុន ៖ មិនគ្រប់ក៏ត្រូវតែគ្រប់។ ចាប់ក្តាមចាប់កង្កែបទៅដុតស៊ីផ្សំទៅ។ ស្លលាយប្រាច់លាយអីស៊ីទៅ។

ប្រុញ ៖ ទៅហ្នឹងមានទឹកមានអីប្រើប្រាស់គ្រប់គ្រាន់ទេមីង?

ជុន ៖ ទឹកស្រែដែរមាន។

ប្រុញ ៖ នៅហ្នឹងពេលធ្វើការនៅហ្នឹងឈឺទេ?

ជុន ៖ ឈឺ!

ប្រុញ ៖ មានឈឺច្រើនទេ រាកមូល?

ជុន ៖ មានតើ ។ ប៉ុនឈឺរកមូលហើយនៅតែខំធ្វើការ ព្រោះខ្លាចព្រោះជំនាន់កាលនោះស៊ើបជីង ដូចថាប្រវត្តិយើងមានបងប្អូនធ្វើទាហាន ឬស្អី យើងធ្វើការមិនពេញលេញគេថា យើងសតិអារម្មណ៍ ។

ប្រុញ ៖ អ្ហូ?

ជុន ៖ អ្ហឺ! សតិអារម្មណ៍ តាមដានដឹងថាយើងមានសរសេរអញ្ចេះអញ្ចុះទៅ បាត់ខ្លួន ។

ប៊ុនថន ៖ ចុះមានធ្លាប់អ្នកមានខ្សែអីគេស៊ើបជីងទេ?

ជុន ៖ ខ្សែស៊ើបជីង ។ នេះគេដឹងក៏គេយកទៅសម្លាប់ ។

ប៊ុនថន ៖ ប៉ុន្តែធ្លាប់មានទេ?

ជុន ៖ ធ្លាប់មាន ។

ប៊ុនថន ៖ ពីណាមីងនៅចាំទេ?

ជុន ៖ ផ្ទះអ្នកនោះ ផ្ទះបងជីដូនមួយខ្ញុំ ។ ប៉ុនប្អូននៅខាងមុខសាលាឃុំ ឈ្មោះ សូម ។

ប្រុញ ៖ សោម?

ជុន ៖ បាទ! សោម ។

ប្រុញ ៖ គាត់ដោយសារម៉េចបានជាគេវាយចោល?

ជុន ៖ បង១ ។ វាយចោលរឿងធ្វើការមិនពេញលេញ ចឹងក៏គេ ។

ប្រុញ ៖ ធ្វើការមិនពេញលេញហើយគេចោទថាមានជាប់?

ជុន ៖ ដូចថាយើងជាប់ម៉េចជីង ។

ប្រុញ ៖ សម័យ លន់ នល់?

ជុន ៖ ចា៎! បើគេថាមិនយកទៅសម្លាប់ទេ គេថាយកទៅកសាងខ្លួនឲ្យបានល្អ ប៉ុន្តែសំពត់ ខោអាវ គេចែកឲ្យពួកធ្វើការនោះទាំងអស់ ។

ប៊ុនថន ៖ អ្ហូ! គេយកចែក?

ជុន ៖ ចា៎! ទាំងភួយទាំងមុង ទាំងអស់ ។

ប៊ុនថន ៖ ប៉ុនអត់ដឹងយកទៅសម្លាប់នៅណាទេ?

ជុន ៖ អត់ទេ ។ អត់ប្រាប់ថាយកទៅស្លាប់ទេ គេថាយកទៅកសាងខ្លួនឲ្យបានល្អ ។ នោះប្រុស ជីដូនមួយ ។

ប៊ុនថន ៖ ចោះមីងដូចនៅនោះអ្នកឈឺអីគេបញ្ជូនទៅណាដែរ ឬមួយគេព្យាបាលនៅកន្លែង?

ជុន ៖ មានពេទ្យគេព្យាបាល ។

ប៊ុនថន ៖ មានពេទ្យគេនៅហ្នុងដែរ?

ជុន ៖ ពេទ្យតាម ។

ប៊ុនថន ៖ គេហៅពេទ្យអីគេវិញអ្នកមីង?

ជុន ៖ ហៅពេទ្យអី!

ប៊ុនថន ៖ ពេទ្យចល័ត ឬមួយពេទ្យ?

ជុន ៖ ពេទ្យចល័ត ។ ពេទ្យភូមិនៅតាមភូមិ ។ ពេទ្យចល័តនៅតាមចល័ត ប៉ុន្តែមានតែថ្នាំសូទ្យស្ពី ៗហ្នឹងឯង ។

ប៊ុនថន ៖ ចុះដូចថាអ្នកធ្ងន់ធ្ងរ គឺគេយកទៅណាវិញ?

ជុន ៖ ធ្ងន់ធ្ងរទៅពេទ្យធំ ពេទ្យស្រុកគេដែរមានតើ ។ បើមិនជាទេ ឈឺខ្លាំងឲ្យមកផ្ទះវិញ មកព្យាបាលនៅផ្ទះ ។ មកម៉ែឪទៅ មានពេទ្យភូមិខ្មែរឱសថបុរាណ ។

ប៊ុនថន ៖ មកអីចឹងរបបម៉េចដែរអ្នកមីង?

ជុន ៖ របបស៊ីរបបផ្ទះ ។ បបរក៏បបរ ម៉ែឪបបរ វាលរបបចែកគ្នា ។

ប្រុញ ៖ កាលនៅដើមគរបើដើម ពីណាគេអ្នកទទួលខុសត្រូវដែរហ្នឹង?

ជុន ៖ កងនោះខ្ញុំមិនស្គាល់ទេ ។ ហៅតែទៅៗ មិនដឹងពីណា ចាំមើលកាលហ្នឹងមិនដឹងពីណា ។

ប្រុញ ៖ ហ្នឹងនៅហ្នឹងស្លាប់អត់ អ្នកធ្វើការនៅហ្នឹង?

ជុន ៖ ស្លាប់ និង ។

ប្រុញ ៖ ស្លាប់ដោយសារអីគេ?

ជុន ៖ ស្លាប់ និងបាត់ខ្លួន ដូចថា យើងធ្វើការមិននេះទៅ នេះទៅបាត់ ។

ប៊ុនថន ៖ ចុះក្រុមមីងមានបាត់ ក្រុមទៅជាមួយ មួយក្រុម?

ជុន ៖ អត់បាត់ទេ មានបាត់ទេ ។ បើបងខ្ញុំ ក្រុមផ្សេងបានបាត់ បងជីដូនមួយ ។ ក្រុមផ្សេងក្រុមគេដូចថា អាយុស្រទាប់លើទៅទៀត ព្រោះខ្ញុំបានលើ ម៉ាក្រោមមកមានកុមារម៉ាក្រោមនោះទៀត ។

ប្រុញ ៖ ជំនាន់ហ្នឹងអ្នកមីងអាយុប៉ុន្មានហើយ?

ជុន ៖ អាយុ១៨ ។

ប្រុញ ៖ ១៨ឆ្នាំ?

ជុន ៖ ចាំ!

ប្រុញ ៖ កាលទៅធ្វើដើមគបីដើមហ្នឹង?

ជុន ៖ ចាំ! ១៨ឆ្នាំ ។

ប្រុញ ៖ ចោះម៉ោពីនោះទៅ មកកំបោរ?

ជុន ៖ កំបោរស្រេះ ។ កំបោរស្រេះរួច ឡើងមកដល់ភូមិនឹងប៉ុស្តិ៍ចាស់ទៅ បានខ្ញុំសុំគេនៅភូមិ ព្រោះម៉ែខ្ញុំឈឺ ។

ប៊ុនថន ៖ គេអត់ថាអីដែរអ្នកមីងសុំគេមក?

ជុន ៖ សុំមកភូមិ ។ ម៉ែខ្ញុំឈឺក៏មកមើលម្តាយទៅ ផុតពីហ្នឹងយើងធ្វើការទៅ ចេញពីធ្វើការទៅ ល្ងាចឡើងបានដេកជុំម្តាយវិញ ។

ប្រុញ ៖ កាលនៅកំបោរស្រេះហូបអីគ្រប់គ្រាន់អីដែរ អត់ទេអ្នកមីង?

ជុន ៖ ហូបបាយមានត្រីមានអី គេចែកមានគ្រប់ឲ្យអ្នកធ្វើការ ។ ម្នាក់បីម៉ែត្រកន្ទះ បីម៉ែត្រគូបកន្ទះ ។

ប្រុញ ៖ នៅកំបោរស្រេះ?

ជុន ៖ ចាំ! ទំនប់កំបោរស្រេះយើង ។ បីម៉ែត្រគូបកន្ទះ រួចឈប់ទៅ ។ រួចថ្ងៃប៉ុណ្ណាក៏ឈប់ទៅ ក៏បាយពេញរបប ។

ប៊ុនថន ៖ ចឹងមីងដកមកម៉ាកងមីងពីគបីដើមមកនេះធ្វើទាំងអស់គ្នា ឬក៏ដកតែមីងទេ?

ជុន ៖ ទេដកទាំងអស់គ្នា មកក៏បែកគ្នាទៅ ភូមិណាក៏ទៅតាមភូមិរៀងខ្លួនទៅ ។

ប៊ុនថន ៖ ប៉ុនម៉ាកងមីង?

ជុន ៖ ចាំ!

ប៊ុនថន ៖ ម៉ាកងមីងមកទាំងអស់?

ជុន ៖ មកទាំងអស់ ។

ប៊ុនថន ៖ ចោះ មី អីនោះមកដដែល?

ជុន ៖ មកគេប្រធានកងគេនៅឯណោះឯង ដឹងប្រពន្ធបងវ៉ៃ ដឹងអ្នកចល័តមកពីខាងទេនាំប្រពន្ធគេមក ។

ប្រុញ ៖ ពេលនៅនេះស្នាក់នៅៗណាវិញ ពេលសម្រាកពេលយប់?

ជុន ៖ ដែលលើកទំនប់!

ប្រុញ ៖ បាទ?

ជុន ៖ សង់រោងតាមវាលស្រែ ។ សង់រោង ចងសំពត់កៅស៊ូដេក ។

ប្រុញ ៖ យប់ភ្លៀង យប់អី?

ជុន ៖ ចាំ! ទាល់តែរួច ភ្លៀងយ៉ាងណាក៏យើងចេះតែចាប់ចង ឲ្យតែបានជិតខ្លួន បើមិនជិតដេក ហាលភ្លៀងខ្លះ ។

ប្រុញ ៖ មានកន្ទេលមានអី?

ជុន ៖ កន្ទេលម្នាក់មួយទៅពីផ្ទះដាក់ស្ពាយទៅ ។

ប្រុញ ៖ មុងភួយអីមានដែរ?

ជុន ៖ ចាំ! មុងភួយខ្លួនឯង សំពត់ខោអាវ ។

ប្រុញ ៖ យើងដាក់ទៅខ្លួនឯង?

ជុន ៖ ចាំ!

ប្រុញ ៖ ពេលហ្នឹងមានគេបញ្ជាយើង នៅមើលយើងនៅហ្នឹងតែម្តង ឬយ៉ាងម៉េចដែរអ្នកមីង ពេល យើងធ្វើនៅហ្នឹង?

ជុន ៖ បញ្ជា ។

ប្រុញ ៖ បាទ?

ជុន ៖ មើលធ្វើស្អាតមិនស្អាត ។

ប្រុញ ៖ មើលប្រាប់យើងធ្វើ?

ជុន ៖ ធ្វើចំនួនបីម៉ែត្រគូបកន្លះ មានដីកតែបីម៉ែត្រគូបកន្លះ មានដីកមានចាំងដាទេរប្រឡាយ ។ ឲ្យមានទេ ឲ្យស្អាត កុំឲ្យយើងរួចហើយ មិនពេញបីម៉ែត្រគូបទុកឲ្យគេអ្នកក្រោយនៅ អត់បានទេ ។ ដូចថាវាវាស់ឲ្យហើយ គេចរៗហើយយកត្រឹមចរ បើថាយើងលឿនមុនគេ យកត្រឹមចរទៅ កុំទុកឲ្យគេនៅ បើទុកឲ្យគេនៅមានកសាងយកទៅវាយចោលទៀត ។

ប្រុញ ៖ ចោះយប់ឡើង ថ្មើរមាណបានៗសម្រាក?

ជុន ៖ អ្ហា!

ប្រុញ ៖ ធ្វើការថ្មើមាណបានៗសម្រាក?

ជុន ៖ យប់ម៉ោង៩ ឬក៏ម៉ោង១០ ។

ប្រុញ ៖ ៩ម៉ោង១០យប់?

ជុន ៖ ថ្ងៃបីម៉ែត្រគូបកន្លះ យប់ពីរម៉ែត្រគូបកន្លះ ។

ប្រុញ ៖ អ្ហូ! ធ្វើយប់ផងថ្ងៃផង?

ជុន ៖ យប់ ចាំ!

ប្រុញ ៖ ចោះហ្នឹងហេតុអ្វីបានគេឲ្យធ្វើយប់ទៀតព្រោះយើងធ្វើពីថ្ងៃហើយបីម៉ែត្រគូបកន្លះហើយ?

ជុន ៖ យប់ធ្វើល្មេចបានសម្រុកឲ្យបានឆាប់រួច វាស់ដូចគ្នាប្រពន្ធ័ប្រឡាយ ។

ប្រុញ ៖ អាចធ្វើហើយទេអ្នកមីងបើសិនជាថ្ងៃ ?

ជុន ៖ ធ្វើត្រូវតែធ្វើហើយ រួចដូចតែគ្នាទាំងអស់គ្នានោះ ។ បើមិនរួចដែលតាមគេដាក់ទិស វាមិនបានបាយស៊ីប៉ុណ្ណឹង ។

ប្រុញ ៖ ពេលដែលធ្វើដល់យប់ថែមពីរម៉ែត្រគូបកន្លះអ្នកមីងនិយាយអំបាញ់មិញថា ថែមពីរម៉ែត្រគូបកន្លះអ្នកមីង?

ជុន ៖ ចាំ!

ប្រុញ ៖ ហ្នឹងអ្ហី! ហេតុអីបានគេឲ្យធ្វើហ្នឹង ហើយរយៈពេលធ្វើហ្នឹងម៉ោយូរប្តូរមួយក៏ម៉េចដែរ?

ជុន ៖ យូរតើ ។

ប្រុញ ៖ អត់ទេ! ខ្ញុំសូមសួរសារថ្មី មានន័យថាដំបូងឡើងគេឲ្យធ្វើតែបីម៉ែត្រគូបកន្លះទេត្រូវទេ?

ជុន ៖ ថ្ងៃ!

ប្រុញ ៖ បាទ?

ជុន ៖ យប់ដូចយើងធ្វើពីក្បាលល្ងាច រាំតែដល់ងុយដេក ។

ប្រុញ ៖ រាល់ថ្ងៃតែម្តង?

ជុន ៖ ចាំ! រាល់ល្ងាច ណោះទំនប់កំបោរស្រែះ បើអីណាក្រៅខ្ញុំមិនដឹងទេ ។ ទំនប់កំបោរស្រែះដែលខ្ញុំធ្វើផ្ទាល់ ។

ប្រុញ ៖ ចឹងសរុបទៅក្នុងម្នាក់ចូលប្រាំមួយគូបហើយចឹង?

ជុន ៖ ចាំ!

ប្រុញ ៖ រាល់ហើយ តាំងពីធ្វើមកប្រាំមួយគូបរហូត?

ជុន ៖ ចាំ!

ប្រុញ ៖ អីចឹងយប់សម្រាក ដល់ម៉ោង៩បានៗសម្រាក?

ជុន ៖ ចាំ!

ប្រុញ ៖ ម៉ោងប៉ុន្មានបានឡើងធ្វើវិញទៀត?

ជុន ៖ ម៉ោងប៉ុន្មាន! ប៉ុនហូបបាយល្ងាចរួច ចាប់សម្រាកមួយសន្ទុះនាំគ្នាធ្វើទៀត ។ ប្រធានកងគេខ្លាំងណាស់ ប្រធានកងកាលជំនាន់ហ្នឹង ។

ប្រុញ ៖ ឈ្មោះ ម៉ុ?

ជុន ៖ ហ្នឹងហើយ ។ ខ្ញុំធ្វើដល់មកនេះ ខ្ញុំសុំថាម៉ែខ្ញុំឈឺ គេឲ្យសម្រាកទៅ ។ តែសុំច្បាប់ដល់គេហើយ គេឲ្យសម្រាក ថាម៉ែឈឺ ។

ប៊ុនថន ៖ ចោះធ្វើចឹង មីងដូចអ្ហឹមានអ្នកអ្ហឹធ្វើអត់បានទេដូចថាវាច្រើន វាការងារច្រើនហើយរហូតដល់យប់?

ជុន ៖ មានអ្នកអត់បាន ។ ចាំ!

ប៊ុនថន ៖ ចោះគេម៉េច គេយកអ្នកអត់បាន?

ជុន ៖ បន្ទុយរបបស៊ី ។ ប្រធានកងនោះ បើធ្វើមិនបានគេថាទៅ ។

ប៊ុនថន ៖ គេវាយការណ៍ទៅលើ?

ជុន ៖ វាយការណ៍ទៅលើទៅទៀត ។ ហីទៅធ្វើថ្ងៃក្រោយ បើថាយើងឈឺមែនគេអត់ថាអីទេ បើយើងគេថាកាលជំនាន់ហ្នឹង គេថាយើងឈឺសតិអារម្មណ៍គេតាមដាន ។ តែយើងមានប្រវត្តិបងប្អូនអ្នកធំក៏គេឲ្យទៅរៀនសូត្រ បញ្ជូនទៅរៀនសូត្រតទៅទៀត ។

ប៊ុនថន ៖ ប៉ុនមានដកចេញទេ ដូចថាអ្នកដែលធ្វើអត់បានអីចឹង មានដកចេញពីកង ហៅទៅណាផ្លាស់ប្តូរទៅណាទេមីង?

ជុន ៖ មាន ។

ប៊ុនថន ៖ ចោះអ្នកទាំងហ្នុងមីងដឹងថាទៅណា?

ជុន ៖ អត់ដឹងថាគេទៅណាទេ គេថាទៅ ។

ប៊ុនថន ៖ តែដែលឃើញមកទេ ត្រឡប់មកវិញទេ?

ជុន ៖ ថាគេបញ្ជូនទៅស្រុកក៏ទៅស្រុកទៅ ។

ប៊ុនថន ៖ ភាគច្រើនអ្នកថ្មី ឬមួយអ្នកចាស់អ្នកមីង?

ជុន ៖ អ្នកចាស់ក៏តាមាន អ្នកថ្មីក៏តាមានទាំងអស់ មាន ។

ប្រុញ ៖ ហេតុអីបានគេមាន ការប្តូរមេកងមេអី?

ជុន ៖ មិនដឹងទេ ខ្ញុំមិនដឹងដែរដល់ហ្នឹង ។ អ្នកធ្វើការខំតែធ្វើការ មិនបានទៅថាតាមដានថា ទៅណេះទៅណោះទៅណាមែន ។

ប្រុញ ៖ ហីយើងធ្វើមួយថ្ងៃជីកប្រាំមួយគូបហើយ ហូបអត់គ្រាន់ឬក៏ម៉េចដែរ?

ជុន ៖ ហូបតាមកំណត់របប តែរបបត្រូវវាល់បាយឲ្យយើងរួចហើយឲ្យយើងឆ្អែតហើយ ។ បើថាយើងមិនរួចបានបន្ទុយរបប ម៉្លោះហើយមនុស្សយើងមិនសុខចិត្តឲ្យស៊ីមិនពេញលេញ សុខចិត្តខំ ។ នេះទំនប់កំពោរស្រែះងាប់ច្រើន ។

ប្រុញ ៖ ស្លាប់ច្រើន ស្លាប់ដោយសារម៉េចដែរ?

ជុន ៖ ស្លាប់ដេកស្លាប់ក៏មាន ដូចថា នឿយ សូវអីទៅដេកស្លាប់ទៅណ៎ា ។

ប្រុញ ៖ គាត់ស្លាប់ដោយសារអ្ហឹហូបអត់សូវឆ្អែត ហើយធ្វើការហត់ហើយ?

ជុន ៖ ចោះឯងដឹង ។ ចា៎!

ប្រុញ ៖ នៅហ្នឹងមានទឹកមានអីប្រើគ្រប់គ្រាន់ទេ?

ជុន ៖ ទឹកគេដឹក មិនដឹងដឹកពីខាងណាទេទឹក ។ ទឹកត្នោតអីដឹកទៅដល់ទាំងពុយៗទៅចែកដឹក ។

ប្រុញ ៖ ហើយហូបគ្រប់គ្រាន់ទេនៅហ្នឹង?

ជុន ៖ ម្ហូបអីមានត្រីមានបីចេងយកទៅឲ្យ ឲ្យតែអ្នកធ្វើការ តែអ្នកមិនធ្វើការអត់ឲ្យទេ ។

ប្រុញ ៖ ទឹកគេឲ្យយើងហូបតាម ឧទាហរណ៍តាមម៉ោងឬក៏តាមអីដែរអ្នកមីង ឧទាហរណ៍ឥឡូវយើងធ្វើការពីម៉ោងអ្ហឹ៦ព្រឹកដល់ម៉ោង១២ថ្ងៃឧទាហរណ៍ ហើយយើងធ្វើរយៈពេលហ្នឹងអត់បានហូបអីទេ គឺមានតែទឹក?

ជុន ៖ អត់បានហូបអីទេ មានតែទឹក ។

ប្រុញ ៖ ទឹកគេឲ្យយើងចែកហូបតាមសេរីឬក៏ម៉េចដែរ?

ជុន ៖ ទឹកសេរី ។

ប្រុញ ៖ ព្រោះអីធម្មតាយើងធ្វើការហត់ត្រូវហូបទឹកអីចឹង?

ជុន ៖ ចា៎!

ប្រុញ ៖ ប៉ុន្តែគេឲ្យ?

ជុន ៖ បើបាយមានដល់ពេលថ្ងៃម៉ោង១១អី ។

ប្រុញ ៖ ពេលព្រឹកព្រលឹមៗឡើងគេអត់មានឲ្យយើងហូបអីទេ?

ជុន ៖ អត់មានទេៗ ។

ប្រុញ ៖ ទឹកនៅហ្នឹងគាត់ គាត់ភាគច្រើនទៅដួសនៅប្រើប្រាស់នៅណា?

ជុន ៖ ស្រះស្រះ ស្រះស្រុកស្រះ ។

ប្រុញ ៖ យើងមកដងមកអីនៅហ្នឹងគេអត់ថាអីទេ?

ជុន ៖ អត់អីទេ គេដឹកទៅឲ្យ ។ មានដូចថាចាត់តាមភូមិ ដូចថាចាស់ៗប្រុសៗអីគាត់មានគោរទេះអី ភូមិគេចាត់ដឹកមកជាកាដុង ធុង ដឹកយកមកទុកតាមកន្លែងមុខព្រួញ ។

ប្រុញ ៖ ឧទាហរណ៍ថាមានស្រះក្នុងវត្តអីចឹងមួយ ហើយគាត់ធ្វើការនៅនោះគាត់អាចមកដងខ្លួនឯង?

ជុន ៖ អត់ដងខ្លួនបានទេ គេដឹកយកទៅចែក ។

ប្រុញ ៖ ដឹកយកទៅចែកតែម្តង?

ជុន ៖ ទៅចែកតាមកង តាមក្រុម ។

ប្រុញ ៖ ចោះទឹកមុជ ទឹកអីឱុបម៉េចគ្រាន់ទៅ បើសិនជាដឹកឲ្យគាត់?

ជុន ៖ តាមតាពាំង ទឹកល្អកទឹកអីក៏មុជទៅ ។

ប្រុញ ៖ មុជទឹកដែលដឹកនៅតាមព្រែកហ្នឹងទៅ?

ជុន ៖ ចា៎! យូរណាស់ហើយ ឡើងចូលប៉ុន្មានសាមសិបឆ្នាំជាង ខ្ញុំថាភ្លេចអស់ហើយ ។

ប្រុញ ៖ ប៉ុនខ្ញុំគិតថាការឈឺចាប់អត់ងាយភ្លេចទេអ្នកមីង ព្រោះអីយើងបានឆ្លងកាត់អីចឹងៗមក ហើយធ្វើហត់ អីចឹងនឹកអត់ភ្លេចទេ?

ជុន ៖ ចា៎!

ប៊ុនថន ៖ ចោះអ្នកមីងមកភូមិនេះ មកនៅជាមួយម្តាយបានយូរទេ រយៈពេលប៉ុន្មាន?

ជុន ៖ ខ្ញុំបានគ្រួសារសម័យបដិវត្តន៍ដែលខ្ញុំមកនៅជាមួយម៉ែខ្ញុំ ម៉ែខ្ញុំថាគាត់នោះឯងឈឺ គាត់ឲ្យបានគ្រួសារកាលនោះចាស់ៗជួយនិយាយទៅ រាយការណ៍ប្រាប់អង្គការ ។ បងប្អូនម៉ែខ្ញុំត្រូវជាជីទូតមួយម៉ែខ្ញុំ ។

ប៊ុនថន ៖ អូ! ត្រូវជាបងប្អូនគ្នាទេ?

ជុន ៖ ចា៎! ជីទូតមួយ ។

ប៊ុនថន ៖ គាត់កាលហ្នឹងគាត់ធ្វើអីដែរ?

ជុន ៖ គាត់មានធ្វើអីទេ ។

ប៊ុនថន ៖ គាត់នៅភូមិដែរ?

ជុន ៖ នៅភូមិ ។ គាត់បង្រៀនកុមារ ។

ប៊ុនថន ៖ អូ! គ្រូបង្រៀន?

ជុន ៖ ចា៎! បង្រៀនកុមារ គ្រូបង្រៀន ។ យើងចេះអក្សរធម្មតាទៅ ក៏ចេះតែបង្រៀនៗកុមារ ។ ប្រធានភូមិគេចាត់ឲ្យបង្រៀន ។

ប្រុញ ៖ អ្នកមីងកាលរៀនការនៅពេលហ្នឹងដែរ?

ជុន ៖ សម័យនោះ ចា៎!

ប្រុញ ៖ នៅអំឡុងពេលធ្វើការនៅហ្នឹងដែរ ឬម៉េចដែរ?

ជុន ៖ ក្នុងភូមិ ។

ប្រុញ ៖ ក្នុងភូមិ?

ជុន ៖ ភូមិតាប៉ែន ចាំ!

ប្រុញ ៖ កាលការ ជំនាន់អ្នកមីងការច្រើនទេ?

ជុន ៖ ប្រាំពីរគូរ ។

ប្រុញ ៖ ស្នើសុំអង្គការរៀបការតែម្ដង?

ជុន ៖ ដូចថាគេនោះមានមួយគូណេះមានមួយគូទៅ ដល់ថ្ងៃថាគេឲ្យរៀបការ ក៏គេហៅ ។ ប្រធានភូមិយកមក គេប្រជុំគ្នា ។

ប៊ុនថន ៖ គេដែលចាប់ផ្គូរផ្គងយកៗតែម្ដងទេអ្នកមីង?

ជុន ៖ អត់ទេ! នៅតាមភូមិអីចឹងស្រេចតែចាស់ៗ ដែលគាត់នេះទៅចង់បាន ក៏គេរាយការណ៍ប្រាប់ប្រធានភូមិទៅ ។

ប្រុញ ៖ អត់ដែលមានថា ឥឡូវដល់ពេលខែត្រូវការអង្គការ?

ជុន ៖ ទេគាត់ទៅតាមមុខព្រួញ មិនមែនមុខព្រួញចាប់ហើយ ។

ប្រុញ ៖ មិនមែនមុខព្រួញគេចាប់?

ជុន ៖ ចាំ! មុខព្រួញ បើថាស្រលាញ់ហើយប្រាប់ប្រធាន ប្រាប់ប្រធានគេ ។

ប៊ុនថន ៖ ចោះមានអ្នកថ្មីដែរទេអ្នកមីង ការអ្នកថ្មី?

ជុន ៖ អ្នកថ្មីមានខ្លះៗ ដូចជាមិនសូវមាន ។ ភ្លេច មានការនោះតែខ្ញុំវាភ្លេចរឿងគេ ។

ប៊ុនថន ៖ បាទ! ប៉ុន្តែអ្នកថ្មីហើយជាមួយអ្នកចាស់អីមានដែលស្នើរៀបការបានទេ ក៏អត់ដែលមានទេមីង?

ជុន ៖ ទេដូចមិនមាន ។

ប៊ុនថន ៖ បាទ! មានតែអ្នកថ្មីជាមួយអ្នកថ្មី?

ជុន ៖ ចាំ!

ប៊ុនថន ៖ ម៉េចចឹងមីង ដូចថាកាលហ្នុងគេហាមឃាត់ ហីក៏?

ជុន ៖ ទេមិនមានហាមឃាត់ទេ ស្រេចតែគេស្ម័គ្រចិត្តចាំ ។

ប្រុញ ៖ ចុះបើមានអ្នកស្នើហើយ ខទាហរណ៍ខាងស្រីគេអត់ព្រមអីតើបានទេអ្នកមីង?

ជុន ៖ អត់ព្រមបានតើនៅក្នុងភូមិហ្នឹង ។

ប្រុញ ៖ គេអត់ថាអីយើងទេ?

ជុន ៖ អត់ថាអីទេ ។

ប្រុញ ៖ ចុះបើតាមមូលដ្ឋានធ្វើការវិញ គេស្នើសុំហើយអត់ព្រមម៉េចដែរអ្នកមីង?
ជុន ៖ ខ្លាចគេក៏ចេះតែទ្រាំទៅ ។ ខ្លាចគេអ្នកកាន់កាប់ ។
ប៊ុនថន ៖ មីងការហើយនៅណាទៀត នៅភូមិដដែល ឬមួយក៏?
ជុន ៖ ភូមិដដែល ចា៎!
ប៊ុនថន ៖ មីងធ្វើអីវិញ?
ជុន ៖ ដាំដំឡូង ។
ប៊ុនថន ៖ ដាំដំឡូង?
ជុន ៖ ចា៎! ដាំដំឡូង គ្រួសារខ្ញុំភ្ជួរស្រែ ។ ថ្ងៃណាដែលឈប់ភ្ជួរទៅ ក៏គាត់បង្រៀនកុមារទៅ ។
ប៊ុនថន ៖ ចឹងនៅក្នុងភូមិនេះ?
ជុន ៖ ចា៎! នៅក្នុងភូមិ ។
ប៊ុនថន ៖ ចុះនៅក្នុងភូមិរបបអាហារម៉េចដែរ ដូចថាបានហូបគ្រាន់បើ?
ជុន ៖ មិនគ្រាន់បើទេ ។ បើគេបើកអង្ករឲ្យទៅក៏ដាំបាយលាយត្រកួន លាយក្តិលល្ហុង ក្តិលចេក ។
ប៊ុនថន ៖ ប៉ុន្តែការងារដូចអត់សូវយ៉ាប់យឺន?
ជុន ៖ មិនយ៉ាប់ទេ ប៉ុនដល់ពេលដាំដំឡូង ម្នាក់ជីករងដំឡូង១០០ម៉ែត្រមួយថ្ងៃឲ្យបាន ។ ក្នុងមួយថ្ងៃឲ្យបានមួយរយម៉ែត្រ រងដំឡូង?
ប៊ុនថន ៖ បណ្តោយមួយរយម៉ែត្រ ចុះទទឹងរង?
ជុន ៖ ទទឹងយើងរងនេះ ។
ប៊ុនថន ៖ អ៊ីចឹងមីងនៅដាំដំឡូងនោះរហូតដល់បែកសម័យ៧៩អ្នកមីង?
ជុន ៖ បាទដល់មានកូនមានអីរហូត ។
ប៊ុនថន ៖ ដល់ពេលបែក៧៩ភ្លាមមីងទៅមកភូមិវិញ?
ជុន ៖ មកភូមិចាស់យើង ។
ប៊ុនថន ៖ ជាមួយពូ?
ជុន ៖ ចា៎! គាត់ គាត់មានអី គាត់ជុតភ្ជួរស្រែបង្រៀនកុមារបន្តិចៗ ។
ប៊ុនថន ៖ កាលហ្នឹងមីងមានកូននៅកាលការ?
ជុន ៖ ខ្ញុំមានកូននៅសម័យនោះតែស្លាប់ ។ ដល់៧៩ ខ្ញុំមកកើតនៅនេះមួយទៀត ។
ប្រុញ ៖ ស្លាប់ៗដោយសារអីអ្នកមីង?
ជុន ៖ ជំងឺ ។ កូនកើតមកបានប៉ុន្មានខែ ស្លាប់ទៅណា ។

ប្រុញ ៖	កាលហ្នឹងអ្នកមីងបាននៅជាមួយកូនជាមួយអីដែរអ្នកមីង?

ជុន ៖	កូនកើតមកបានប៉ុន្មានកន្លះខែស្លាប់ ។ ស្លាប់ក៏ធ្វើការដាំដំឡូងតទៅទៀត?

ប្រុញ ៖	គាត់ស្លាប់ដោយសារជំងឺកូន?

ជុន ៖	ចា៎! ជំងឺ ។

ប៊ុនថន ៖	ចោះមីងបែក៧៩មកនៅភូមិអត់មានទៅណាទៀតទេ?

ជុន ៖	អត់មានទៅណាទេ នៅនេះរហូត ។

ប៊ុនថន ៖	លោកពូគាត់នៅគ្រូបង្រៀនឥឡូវ?

ជុន ៖	បង្រៀនម្ដងៗ ខែស្រែក៏ធ្វើស្រែទៅ ។

ប៊ុនថន ៖	ប៉ុនរហូតសព្វថ្ងៃនេះគាត់នៅបង្រៀនទេ?

ជុន ៖	ទេ! សព្វថ្ងៃនេះគាត់ធ្វើការនៅកន្លែងនេះ ចាប់ពីកន្លែងខេត្ត ខាងទេសចរណ៍ ។

ប៊ុនថន ៖	មន្ទីរទេសចរណ៍?

ជុន ៖	ចា៎! មន្ទីរទេសចរណ៍ខេត្ត ។

ប៊ុនថន ៖	ចោះអ្នកមីង?

ជុន ៖	ខ្ញុំធ្វើស្រែ នៅផ្ទះ ។

ប៊ុនថន ៖	សព្វថ្ងៃមានកូនប៉ុន្មាននាក់អ្នកមីង?

ជុន ៖	កូនខ្ញុំតែពីរនាក់ទេ ប៉ុនមួយនៅថៃ មួយនៅរៀនហ្នុង ។

ប៊ុនថន ៖	ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ជុន ៖	ប្រុសទាំងពីរ ។ ស្រីនេះខ្ញុំទើបតែយកមកចិញ្ចឹម ។

ប្រុញ ៖	កូនតូចអំមិញ?

ជុន ៖	ក្មាកំព្រា ចា៎! កំព្រាយកចិញ្ចឹមតាំពីមួយខែ មួយខែ១៣ថ្ងៃខ្ញុំយកមក ។ កូនពីរប្រុសទាំងពីរ បងនៅបើកកប៉ាល់នៅថៃសព្វថ្ងៃ ។ វាមិនមានអីមុខឲ្យកូនធ្វើរក ក៏ឲ្យទៅ ។

ប្រុញ ៖	ចង់សួរអ្នកមីងឲ្យបានលម្អិតអាពាក់ព័ន្ធអាការធ្វើនៅនេះ ធ្វើហ្នឹងបានយូរទេអ្នកមីង បានកាលនៅកំបោរស្រេះធ្វើយូរទេ?

ជុន ៖	យូរដែរតើ យូរឡើងភ្លេច ។

ប្រុញ ៖	ធ្វើយូរ?

ជុន ៖	ចា៎!

ប្រុញ ៖	ខ្វង់ប្រហែលជាធ្វើហ្នុងបានប្រហែលប៉ុន្មានខែ ប៉ុន្មានឆ្នាំដែរអ្នកមីង?

ជុន ៖ ទេមិនដល់ឆ្នាំទេ ។

ប្រុញ ៖ អត់ដល់ឆ្នាំទេ?

ជុន ៖ ចាំ! វាក្មេង មិនបានជាគិតគូរជងហ្នឹង ដឹងថាយូរ ។

ប្រុញ ៖ ហើយស្គាល់អ្នកធំៗ ធ្វើការនៅហ្នឹងខ្លះទេ?

ជុន ៖ មិនដែលស្គាលទេ ស្គាល់ពិតប្រាកដមិនដែលទេ ។ គ្រាន់តែថាគេដើរត្រួតយើង យើងស្គាល់អ្នកនេះអ្នកនោះស្គាល់ មិនបានទេ ។ ចាំ!

ប្រុញ ៖ ហើយជុតពីហ្នឹងទៅមកចូលភូមិវិញ?

ជុន ៖ ចាំ!

ប្រុញ ៖ អ៊ីចឹងមានន័យថា មីងកាលហ្នឹងធ្វើការហត់សម័យធ្វើការនៅកំបោរស្រែះ?

ជុន ៖ ចាំ!

ប្រុញ ៖ នៅហ្នឹងមានគេចម្រាញ់អ្នកដែលអ្វីធ្លាប់ជាអ្នកធ្វើនៅសម័យ លន់ នល់ អីយកទៅសម្លាប់អីអត់ទេអ្នកមីង?

ជុន ៖ ចម្រាញ់ ។

ប្រុញ ៖ ចម្រាញ់ដែរ?

ជុន ៖ ចាំ! ចម្រាញ់ ប៉ុនគេមិនមែនថាយកទៅសម្លាប់ទេ ថាឲ្យទៅរៀនសូត្រៗក៏បាត់ទៅ ។

ប្រុញ ៖ គេស៊ើបអីម៉េចៗទៅមីង?

ជុន ៖ មិនដឹងគេស៊ើបយ៉ាងណាបានជាគេដឹងថា ។

ប្រុញ ៖ គេហៅយើងយកទៅៗបាត់តែម្តង?

ជុន ៖ ចាំ! ឈ្មោះនេះឈ្មោះនោះ គេថាឈ្មោះនេះឲ្យទៅរៀនសូត្រ បំពេញភារកិច្ច ។ ទៅក៏ទៅបាត់ទៅ ស្រាប់តែដល់វគ្គក្រោយតាបាត់ខ្លួនមានតែស្លាប់ ។ ចាំ!

ប្រុញ ៖ ក្នុងអំឡុងពេលធ្វើទំនប់ហ្នឹង?

ជុន ៖ ចាំ!

ប្រុញ ៖ បាត់ច្រើនតែម្តង ឬក៏ម៉េចដែរ?

ជុន ៖ ទេចេះតែបាត់រុយៗទៅ ទៅខាងណាមិនដឹង គេយកទៅណាទៅណើ ។

ប្រុញ ៖ ចុះនៅហ្នឹងមានគេអ្វីស្រាវជ្រាវពាក់ព័ន្ធរកមុខជនជាតិវៀតណាម ជនជាតិអី ជនជាតិចាមអីយកទៅសម្លាប់ចោលអត់អ្នកមីង?

ជុន ៖ ទេខ្ញុំមិនដែលឮជង ។

ប្រុញ ៖ អត់ទេ?

ជុន ៖ ចា៎!

ប្រុញ ៖ ចោះសម័យនោះមានជនជាតិវៀតណាមធ្វើការនៅហ្នឹងច្រើនទេ?

ជុន ៖ មិនដែលមានផង ។

ប្រុញ ៖ អត់មាន មានតែខាងខ្មែរយើងពីភ្នំពេញមក?

ជុន ៖ ពេលចុះប្រវត្តិក៏ថាខ្មែរៗទាំងអស់ ។ បើដឹងថាវៀតណាមក៏បាត់ដែរ គេឲ្យទៅស្រុកទាំងគ្រួសារ ។

ប្រុញ ៖ អូ! បើដឹងវៀតណាមគេឲ្យទៅស្រុកវិញ?

ជុន ៖ ចា៎!

ប្រុញ ៖ នៅហ្នឹងពេលអ្នីមានកំហុសមានអី គេចាប់ហើក៏ម៉េចដែរអ្នកមីង ឬក៏សម្លាប់មានអីដែរ ។

ជុន ៖ មានកំហុសគេចាប់ ចាប់យប់ឡើងគេចាប់ទៅបាត់ឈឹងទៅ ។

ប្រុញ ៖ បាញ់ចោល?

ជុន ៖ បែបមិនបាញ់ទេ បែបវាយ ។ ចា៎!

ប្រុញ ៖ វាយៗចោលកៀនៗហ្នឹង?

ជុន ៖ វាយ កាលនៅតាប៉ែនវាយចោលខាងជើងភូមិ ។ គេយកទៅចា៎!

ប្រុញ ៖ ធ្លាប់ឃើញទេអ្នកមីង?

ជុន ៖ ចា៎!

ប្រុញ ៖ អ្នកមីងធ្លាប់ឃើញទេ?

ជុន ៖ ចា៎! ផ្ទះខ្ញុំនៅមាត់ផ្លូវផង ។ យប់ឡើងម៉ែខ្ញុំគាត់មិនដែលហ៊ានដេកទេ បណ្តើរទៅទីបៗស្រែកយំពេញភូមិ ។

ប្រុញ ៖ គេវាយឲ្យយើងឃើញទេ?

ជុន ៖ អត់វាយទេ ប៉ុនដឹងតែចង ។

ប្រុញ ៖ ព្រលឹមឡើងសល់ខ្មោចនៅហ្នឹងអត់ទេ?

ជុន ៖ អត់សល់ ។ ដឹងយកទៅណាបាត់ ។

ប្រុញ ៖ កាលសម័យហ្នឹងមិនចម្រាញ់ខាងអ្នកធ្វើការសម័យ លន់ នល់ ច្រើនទេកាលធ្វើ?

ជុន ៖ ចម្រាញ់ ។ ខ្មោចឪពុកមាខ្ញុំ ច្រឡំឈ្មោះគ្នា ។ ឈ្មោះ យ៉ា ដូចគ្នា តែលោកឪពុកមាខ្ញុំឈ្មោះ យ៉ា តែគាត់ធ្វើកាប៉ូរ៉ាល់សែប ។ ឈ្មោះ យ៉ា មួយសឹកពីបួសគ្នាធ្វើតែស្រែ

ចាប់ឈ្មោះ យ៉ា នេះហើយយកទៅសម្លាប់ៗ យ៉ា ឪពុកមាខ្ញុំនៅ។ គាត់ទើបនឹងស្លាប់សង្គមនេះឯង។ ដល់ពេលសម្លាប់ឈ្មោះ យ៉ា នោះរួចគេថាប្រឡំៗឪពុកមាខ្ញុំភ័យរត់ៗ

ប្រុញ ៖ អូ! ចាប់បានត្រូវកុន?

ជុន ៖ ចឹងរត់ ដល់ទៅរត់ៗ គាត់ទៅមិនរួច គាត់មកវិញ។

ប្រុញ ៖ អ៊ីចឹងគាត់ទើបនឹងស្លាប់នៅក្រោយ?

ជុន ៖ ចា៎!

ប៊ុនថន ៖ គាត់ត្រឡប់មកវិញពេលបែកហើយក៏ពេលណា?

ជុន ៖ គាត់ត្រឡប់មកវិញភ្លាមៗដែល ប៉ុនដល់គេនឹកឃើញថាអ្នកដែលត្រូវរកគាត់ត្រូវជម្លៀសផ្លាស់កន្លែងទៅទៀត។ អ្នកនោះមកក្រោយ។

ប៊ុនថន ៖ ពីណាអ្នកដែលរកមឹងគាត់ធ្វើអី?

ជុន ៖ ជំនាន់និរតី។

ប៊ុនថន ៖ ខាងនិរតី?

ជុន ៖ គេមកពីខាងនិរតីនោះឯង។ ចា៎!

ប៊ុនថន ៖ គាត់តួនាទីអីវិញអ្នកមឹងអ្នករកនោះ?

ជុន ៖ ចា៎!

ប៊ុនថន ៖ ជាយោធា ឬកម្មាភិបាលភូមិឃុំ?

ជុន ៖ ទេមិនមែនយោធាទេ។ ដឹងជាទាក់ទងពីខាងណាបានមកចាប់ហ្នឹងនៅភូមិ។

ប៊ុនថន ៖ ចឹងបានរួចដោយសារប្រឡំឈ្មោះចឹង?

ជុន ៖ ចា៎! សម័យនោះឪពុកក្មេងខ្ញុំ ឪពុកគាត់ក៏គេចាប់ដែរ។

ប្រុញ ៖ ហើយម៉េចដែរ?

ជុន ៖ ចាប់យប់ទៅបាត់។

ប្រុញ ៖ ចឹងយកទៅបាត់រហូត?

ជុន ៖ រហូតចា៎!

ប្រុញ ៖ គេចោទគាត់ថាម៉េចបានគេចាប់គាត់?

ជុន ៖ គ្រាន់តែគាត់ ថាគាត់មិនដឹងរឿងស្អីទេ។

ប្រុញ ៖ ចាប់យើងអត់ដឹង?

ជុន ៖ ថាគាត់ពីជំនាន់សម័យ លន់ នល់ ថាគាត់ធ្វើ៥០ខ្នង ចឹងមិនដឹង។

ប៊ុនថន ៖ មេ៥០ខ្ទង?

ជុន ៖ មេ៥០ខ្ទងចឹងមិនដឹង នឹងឪពុកគាត់ ។

ប៊ុនថន ៖ គ្រួសារអ្នកមីងឈ្មោះអី?

ជុន ៖ ឈឹម ខៀន ។

ប៊ុនថន ៖ គាត់អ្នកស្រុកហ្នឹងដែរ អ្នកភូមិហ្នឹង?

ជុន ៖ អ្នកនេះឯង ។ ចាំ!

ប្រុញ ៖ ចោះកាលនោះគេចាប់ឪពុកគាត់ គេអត់សួររកកូនគាត់ទេ?

ជុន ៖ សួររកកូនៗនាំគ្នាទៅប្រូតនៅរនាមទាំងអស់ ។ បងប្អូនគាត់បីនាក់ ស្រីមួយប្រុសពីរ ហើយគាត់នៅលើវទាំងអស់គ្នាណាំ នៅលើង ។ បងបានប្តីហើយ ។ ដល់គេទៅថាគេចាប់ គេរកកូនឈ្មោះនោះៗទៅក៏គេចាប់ទាំងអស់គ្នា ទាំងបីនាក់ហ្នឹង ។ ប្តីបងស្រីគេអត់ចាប់ទេ គេយកចេញ ឲ្យតែកូនបង្កើតៗមក ដល់មកអង្គុយអង្គប្រជុំមានប្រធានយោធាម្នាក់ជិះសេះទៅឈ្មោះ តាក្រកៗ ជិះសេះទៅថា ស្តីគេថា បិទម៉ារយៈតូច ។

ប្រុញ ៖ បិទអីគេអ្នកមីង?

ជុន ៖ បិទម៉ារយៈតូច បិទមិនឲ្យសម្លាប់បិទម៉ារយៈតូច ម្រាមដៃណាស្អុយកាត់តែម្រាមដៃនោះបានជាភូមិគាត់បានតែរស់កុំអីត្រូវស្លាប់ទាំងអស់ ។

ប្រុញ ៖ ម្រាមដៃណាស្អុយម៉េចអ្នកមីង?

ជុន ៖ ម្រាមដៃ ដូចថាម្រាមដៃណាស្អុយកាត់ម្រាមដៃនេះចោល ម្រាមដៃជាទុកជា ។ គេសម័យនោះគេនិយាយអញ្ចុះឯង ។

ប្រុញ ៖ អូ! គាត់ចង់និយាយក្នុងមួយគ្រួសារបើមានអ្នកខូចចាំសម្លាប់?

ជុន ៖ ខូចតែម្នាក់ទៅកុំឲ្យសម្លាប់ទាំងអស់ ។

ប្រុញ ៖ អូ! យល់ ហើយ តាក្រក ហ្នឹងគាត់អ្នកជ្រើសរើស?

ជុន ៖ យោធាដឹង ។

ប្រុញ ៖ យោធា?

ជុន ៖ ចាំ!

ប្រុញ ៖ អត់ដឹងគាត់ស័ក្តិប៉ុន្មានអីប៉ុន្មានដែរអ្នកមីង?

ជុន ៖ អត់ដឹងទេ ។

ប្រុញ ៖ ប៉ុន្តែគាត់យោធានៅក្នុងតំបន់ឬក៏យោធាក្នុង?

ជុន ៖ គាត់មកក្តាប់ក្តោបនៅក្នុងឃុំនេះឯង ។

ប្រុញ ៖ នៅក្នុងឃុំ?

ជុន ៖ ចាំ!

ប្រុញ ៖ ចឹងម៉ាជំនាន់នោះកុំតែបាន តាក្រក ហាថាផ្ដាកសម្លាប់មួយគ្រាកុំអីត្រូវអស់ច្រើន?

ជុន ៖ ចាំ! កុំអីអស់ច្រើន កុំអីគាត់គឹងបងប្អូនៗបីនាក់អស់ទាំងបីនាក់ ចោះគេចាប់ឪពុកទៅហើយ ។

ប្រុញ ៖ តាក្រកហ្នឹងទទួលបញ្ជាពីគេបានគាត់ហ៊ានថាឈប់សម្លាប់អី?

ជុន ៖ គាត់អ្នកសម្លាប់ គាត់អ្នកផ្ដាកដោយខ្លួនគាត់ ។ ចាំ!

ប្រុញ ៖ គាត់អ្នកសម្លាប់ខ្លួនគាត់?

ជុន ៖ ចាំ! គាត់អ្នកសម្លាប់ គាត់អ្នកផ្ដាកខ្លួនគាត់ ។ វគ្គក្រោយទៅទៀត ក៏ទៀត តាក្រកៗ ។

ប្រុញ ៖ តាក្រក គាត់នៅរស់ទេអ្នកមីង?

ជុន ៖ ស្លាប់ហើយសព្វថ្ងៃ ។ គាត់ចាស់ហើយ ។

ប្រុញ ៖ ស្លាប់ក្នុងសម័យខ្មែរក្រហមហ្នឹងដែរ?

ជុន ៖ មិនដឹងស្លាប់អន្តាល់ណាទេ ។ ជម្លៀសចេញរៀងខ្លួនទៅបាត់គាត់ មិនដឹងថាគាត់ទៅខាងណា ។

ប្រុញ ៖ ចោះអ្នកមីងប្តូរមកធ្វើការក្នុងភូមិវិញ អ្ហឺបានប៉ុន្មានបានបែកសម័យខ្មែរក្រហម?

ជុន ៖ ខ្ញុំបានកូនមួយហើយ ។

ប្រុញ ៖ អ្ហូ! បានធ្វើការនៅក្នុងភូមិមានគ្រួសារ មានកូនហើយបានបែក?

ជុន ៖ ចាំ! បានបែក ។

ប្រុញ ៖ កាលជំនាន់ហ្នឹងការអីគេឲ្យយើងនៅជាមួយដែរតើមីង?

ជុន ៖ ការបានតែចាប់ដៃគ្នាក៏ទៅតាមមុខព្រួញរៀងខ្លួន ។ គាត់ធ្វើភ្ជួរស្រែ គាត់ទៅនៅតាមស្រែទៅ ។

ប្រុញ ៖ យប់ឡើងប្តីប្រពន្ធគេអត់ឲ្យនៅជាមួយគ្នាទេ?

ជុន ៖ អត់បែកគ្នា ។ មកមុខព្រួញបែកគ្នា ក៏បែកគ្នាទៅ ។ មុខព្រួញជុំគ្នានៅជុំគ្នា ។

ប្រុញ ៖ ពេលមកក្នុងភូមិហ្នឹងនៅតែ តាក្រក កាន់កាប់ដដែលនៅក្នុងភូមិហ្នឹង គាត់អ្នកមើលការខុសត្រូវនៅក្នុងភូមិហ្នឹងដដែល?

ជុន ៖ គាត់អ្នកមើលការខុសត្រូវនៅក្នុងភូមិ ។ បើយើងចល័តមានអ្នកកាន់កាប់ផ្សេង ។

ប្រុញ ៖ នៅហ្នឹងមានគេហៅប្រជុំហៅអីញឹកញាប់អីអត់ទេ?

ជុន ៖ ទេប្រជុំរឿងដែលឲ្យធ្វើការងារអីឲ្យបានទៀងទាត់អី ប្រជុំហ្នឹងឯង ។

ប្រុញ ៖ គេមានហៅប្រជុំតិះទៀនគ្នាអីអត់ទេ ព្រោះខ្ញុំធ្លាប់ឮគេថាមានការប្រជុំតិទៀនគ្នា?

ជុន ៖ តិះទៀតយើងមានកំហុសគេកសាង ។

ប្រុញ ៖ ហីរឿងតិះទៀតយ៉ាងម៉េចដែរ អ្នកមីងអាចនិយាយ?

ជុន ៖ តិះទៀនដូចថាធ្វើការមិនសមស្របជាស្អី១ ពេលដាក់ទិសយើងមិនធ្វើខ្លះខ្លាយស្អី១ ម៉េចទេ ។

ប្រុញ ៖ យើងកូនកងនិយាយតិះទៀនគ្នាទៅ?

ជុន ៖ តិះទៀនគ្នា ។ ចាំ!

ប្រុញ ៖ ហើយចុះដល់ពេលក្រោយពីតិះទៀនមកម៉េចដែរមីង អ្នកដែលត្រូវគេតិះទៀនហ្នឹង?

ជុន ៖ យើងទទួលកំហុសហើយក៏រួចគ្នាទៅ ។

ប្រុញ ៖ គេប្រជុំតិះទៀនហ្នឹងគេប្រជុំញឹកញាប់ទេអ្នកមីង?

ជុន ៖ ទេទាល់តែមានយើងធ្វើការមានកំហុសទៅគេក៏លើកប្រជុំម្តង ។

ប្រុញ ៖ ប៉ុន្មានអាទិត្យគេប្រជុំម្តង ហីក៏ម៉ាអាទិត្យគេប្រជុំប៉ុន្មានដង?

ជុន ៖ ម៉ាអាទិត្យ បួនដប់ថ្ងៃទៅម្តងទៅ ស្រេចគេ ។ គាត់ (ប្តី ឈឹម ខៀន) នោះឯងតែឪគាត់ស្លាប់មិនដែលបាននិយាយ ។

ខៀន ៖ អូ! ខ្ញុំនិយាយរឿង ប៉ុល ពត ខ្ញុំឈឺចាប់ណាស់ ខ្ជិលមានបានប្រយោជន៍អីទេខ្ជិល ។ វាធ្វើម៉េចបានតែថ្នាក់ដឹកនាំក្រោយៗកុំឲ្យមានអញ្ចេះទៀតទៅ ។ ខ្ញុំមើលទៅដឹងវាយ៉ាងម៉េចហើយយើងទៅថាយ៉ាងណា ទៅមិនរួច ធ្វើម៉េចក្រុមគេៗចាត់គ្នាគេ ។

ប្រុញ ៖ កាលនៅកំបោរគេឲ្យប្រជុំតិះទៀនចឹងដែរអ្នកមីង?

ជុន ៖ ប្រជុំរឿងអ្នកធ្វើការប៉ុណ្ណេះឯង មានប្រជុំតិះទៀនអី ។

ប្រុញ ៖ គេប្រជុំជម្រុញយើងឲ្យធ្វើការ?

ជុន ៖ ធ្វើការ ហើយសមស្រប ឲ្យដាក់ទិសទៅឲ្យបានរួច ។

ប្រុញ ៖ គេបង្ខំយើង បង្ខំឬក៏គ្រាន់ថាដាក់ការងារឲ្យធ្វើឲ្យហើយ?

ជុន ៖ ដាក់ការឲ្យហើយប៉ុណ្ណឹង មាននរណាមកឈរបង្ខំយើងទេ ។ គេវាស់ឲ្យយើង ដើរទៅវាស់ទៀតអស់ទៅ ។ ណាំ!

ប្រុញ ៖ គេអត់មានថាធ្វើការអត់ហើយត្រូវទទួលទណ្ឌកម្ម ក៏ប៉ុន្តែគ្រាន់គេកាត់បន្ថយរបប?

ជុន ៖ គាត់បន្ថយរបបនោះឯង ។

ប្រុញ ៖ គាត់បន្ថយនោះបន្ថយរហូតដល់ជិតអស់តែម្តងឬយ៉ាងម៉េចដែរអ្នកមីង?

ជុន ៖ បន្ថយដូចថាថ្ងៃនេះយើងធ្វើរួចបានពេញមកវិញ ។

ប្រុញ ៖ បាទ?

ជុន ៖ ស្អែកយើងធ្វើមិនរួចក៏គាត់បន្ថយមួយពេលទៅ ។

ប្រុញ ៖ គាត់អត់ឲ្យហូបតែម្តងហើយក៏គេឲ្យខ្លះ?

ជុន ៖ ឲ្យខ្លះ ដូចថាបីវែកបន្ថយនៅតែពីរវែក ។ គេវាល់វែកកាលហ្នឹង ។

ប្រុញ ៖ ហីស្អែកអត់ហើយទៀតគេបន្ថយទៀត?

ជុន ៖ ស្អែកអត់ហើយទៀតបន្ថយតាមនោះទៅ ។ ចា៎! បើថាយើងរួចក៏ពេញ ប៉ុនតាបានបាយដើរតាមមុខព្រួញបានបាយ បានម្ហូបអីស៊ីមានគេយកចែកតាមមុខព្រួញបានស៊ីពេញមាត់ពេញកព្រោះគ្នាអ្នកធ្វើការ ។ អ្នកភូមិធ្វើការស្រាលរបបតិចក៏មិនអី ។

ប្រុញ ៖ ប៉ុន្តែគាត់នេះគាត់ដីកដាំដំឡូងដាំអីដែរ?

ជុន ៖ ចា៎! ដាំមានដំឡូងមានស្ពៃទៅ មានស៊ីទៅពេញពោះទៅ ។

ប្រុញ ៖ ជាទូទៅអ្នកដែលអ៊ីអ្នកធ្វើការនៅភូមិធ្វើការនៅតាមមុខព្រួញចឹង គេចង់ធ្វើការខាងណាជាងភាគច្រើនទោះបី?

ជុន ៖ បើនារីយុវជនចង់តែចេញក្រៅ ព្រោះបានបាយស៊ីឆ្អែត ។ ចា៎! បានបាយហូបឆ្អែតគ្រប់មុខព្រួញ ។

ប្រុញ ៖ អ៊ីចឹង?

ជុន ៖ ម៉ែៗគាត់បានចេញទៅណា ចុះនៅក្នុងភូមិទៅដាំដំឡូង ដាំស្ពៃទៅក៏បានហូបទៅ ។ ទោះបីរបបថយក៏បាននោះជួយ បន្លែបន្ថាជួយ ។

ប្រុញ ៖ ចឹងដល់ពេលចប់ពីហ្នឹងអត់បានទៅធ្វើនៅត្រពាំងថ្មត្រពាំងអីទេ?

ជុន ៖ ខ្ញុំអត់បានទៅទេ ។ ចា៎! ត្រពាំងថ្ម ខ្ញុំអត់បានទៅទេ ។

ប្រុញ ៖ ចោះអ្នកភាគច្រើនគេចាត់ទៅត្រពាំងថ្មអ្នកមីង?

ជុន ៖ ភាគច្រើនគេទៅត្រពាំងថ្ម ទៅចម្រុះគ្នា ។ បើអ្នកណាធ្វើការក្នុងភូមិក៏ធ្វើទៅដូចថា ដូចគេតម្រូវក្នុងមួយភូមិបាន៣០នាក់ យកទៅឲ្យអង្គការចុះទៅណេះចុះទៅណោះទៅ ។ ប្រធានភូមិចាត់ចែង៣០នាក់ទៅ ។ ចា៎!

ប្រុញ ៖ អូ! មានប្រធានកងគេផ្សេងៗគេស្នើមកមេភូមិឲ្យជ្រើសរើសកម្លាំងអីចឹងទៅ?

ជុន ៖ ចាំ! ត្រូវការកម្លាំងពលកម្ម ប្រធានភូមិជ្រើសរើសឲ្យទៅ ។

ប្រុញ ៖ កាលទៅពីថ្មកំបោរទៅអ្ហ៎ កំបោរស្រះហ្នឹងទៅសល់មនុស្សច្រើនទេទៅធ្វើការនៅត្រពាំងថ្ម អ្នកមីង?

ជុន ៖ ធ្វើការត្រពាំងថ្មគេធ្វើតាមដូចថា យើងច្រើនស្រុកទៅរួមគ្នា ។ សល់ខាន់ប៉ុន្មានយើងមុខព្រួញជិត ។ មុខព្រួញឆ្ងាយជីង៣០នាក់ បាន៣០នាក់ទៅឲ្យគេ ។ គេត្រូវការប៉ុណ្ណា ។

ប្រុញ ៖ ៣០នាក់ហ្នឹងត្រូវគឺគេយកទៅត្រូវតែទៅ?

ជុន ៖ ត្រូវតែគ្រប់ ។ តម្រូវមកប៉ុន្មាន គឺប្រធានភូមិតម្រូវឲ្យបាន ។

ប្រុញ ៖ គាត់ដែលមានប្រកែកថាអត់ចង់ទៅ ចង់នៅក្នុងភូមិអីអត់?

ជុន ៖ អត់ទេ ។

ប្រុញ ៖ ហៅទៅៗហើយ?

ជុន ៖ ហៅត្រូវឈ្មោះខ្ញុំថាឲ្យទៅភ្នំស្រុកចេះ ក៏រៀបអីវ៉ាន់ ។

ប្រុញ ៖ គាត់ដែលភ័យទេ ភ័យដែលគេអ្ហ៊ីចាប់ ឧទាហរណ៍ថាបញ្ជូនទៅ៣០នាក់អី គាត់ដែលភ័យថាគេយកទៅសម្លាប់?

ជុន ៖ ទេកាលនោះដល់ថាយកទៅលើកទំនប់ យុវជន នារី វាក៏មានអីទេ ។ បើថាចាស់ៗភ័យក្នុងភូមិ ។

ប្រុញ ៖ ម៉េចចាស់ៗបានជាគាត់ភ័យអ្នកមីង?

ជុន ៖ ចោះខ្លះមានប្រវត្តិដូចថាជំនាន់គាត់ធ្វើទាហានធ្វើអី ធ្វើមេក្រុមធ្វើអីសម័យ លន់ នល់ គេត្រូវតែជ្រើសរើស ។

ប្រុញ ៖ ចឹងមកក្នុងភូមិនេះអត់មានរឿងអីត្រូវកត់សម្គាល់ឃើញច្រើនពាក់ព័ន្ធការធ្វើកម្លាំងពលកម្មច្រើនទេអ្នកមីង?

ជុន ៖ អ្ហ៊ី! កត់សម្គាល់អីទេ មកក៏មកទៅ ។

ប្រុញ ៖ ធ្វើការធ្ងន់តាសម័យធ្វើទំនប់នៅកំបោរ?

ជុន ៖ គ្រាន់តែមានចេះប៉ុណ្ណេះ ។ អ្ហូ! សម័យអង្គាល់នោះ បើសិនអង្គាល់នេះមានតែខំធ្វើការឲ្យតែងាប់រៀងៗខ្លួន ។

ប្រុញ ៖ ហ្នឹងគេប្រាប់ម៉េចបានយើងខំធ្វើម្ល៉េះអ្នកមីង?

ជុន ៖ ភ័យ ។

ប្រុញ ៖ ភ័យ! គេធ្លាប់និយាយប្រាប់ម៉េចបានយើងភ័យរហូតដល់ខំធ្វើការឲ្យគេអស់កម្លាំង?

ជុន ៖ ចុះបើយើងឃើញដូចថា គេយកទៅក៏បាត់ទៅ ៗ គេយកទៅណោះក៏បាត់ទៅ ហើយចេះតែភ័យ ៗ

ប្រុញ ៖ ចឹងម្នាក់ៗ ខំធ្វើការដោយសារឃើញគេបាត់ៗ គ្រប់គ្នាចឹង ធ្វើម៉េចខំធ្វើឲ្យតែរស់?

ជុន ៖ ចាំ! ហ្នឹងហើយ សូម្បីដូចថាមាសប្រាក់គេថា គេប្រមូលវ៉ាន់ណាគេមិនឲ្យគេមានដែកដូសដីងដែកឆក់ដីងក៏ចេះតែ នៅក្នុងអាវយើងសោះនៅក្នុងហោប៉ៅយើងសោះក៏ចេះតែយកឲ្យគេហ្នឹង ៗ

ប្រុញ ៖ កាលហ្នឹងគេដកយកអស់តែម្ដងទ្រព្យសម្បត្តិ?

ជុន ៖ ដកយកទាំងអស់ ៗ ចុះចាញ់នយោបាយថា បើនរណាលាក់គេតែគេណែមានស្អីដូសដីងថាមាននៅគេយកយើងទៅសម្លាប់ចោល ក៏ចេះតែនាំគ្នាដាក់ឲ្យគេទៅ ៗ

ប្រុញ ៖ ចុះគេប្រាប់ថាម៉េចបានយើងដឹង អ្ហឺបានយើងខ្លាចរហូតដល់ដកឲ្យគេអស់ អត់លាក់ទុកអីគេម៉េចគេប្រាប់យើងថាម៉េចដែរ?

ជុន ៖ ថាអង្គការស៊ើបដឹង ៗ ដូចយើងដឹងក្នុងគ្នាយើងថា គេថាឲ្យទៅរៀនសូត្រមួយ គេដឹងថាឲ្យទៅរៀនសូត្របាត់ខ្លួនទៅ មានណាយកទៅសម្លាប់ហើយមុខតែនេះ ៗ ក្រោយទៅចេះតែប្រុងប្រយ័ត្ន ខ្លាចទៅណា ៗ

ប្រុញ ៖ ចឹងដល់ពេលគេសួរប្រមូលឲ្យគេអស់ៗ?

ជុន ៖ អស់ ៗ

ប្រុញ ៖ ភាគច្រើនគេយកតែអីខ្លះអ្នកមីង យកទ្រព្យសម្បត្តិយើង?

ជុន ៖ ប្រមូលមាសប្រមូលអី ៗ

ប្រុញ ៖ គោក្របីយើង?

ជុន ៖ គោក្របីដាក់ជារួម

ប្រុញ ៖ ខ្ញុំដូចជាអស់អីសួរអ្នកមីងព្រោះអីសួរសម្អិតហើយ ៗ អ្នកមីងអាចមានអីអីដែលខ្ញុំសួរអត់ដល់អ្នកមីងអាចនិយាយដោយសង្ខេប?

ជុន ៖ និយាយស្អីអស់ហើយ ៗ

ប្រុញ ៖ ខ្លាចសួរអត់អស់ចឹងអ្នកមីងអាចបន្ថែមបាន?

ជុន ៖ បន្ថែមត្រង់ណាបើអស់ ៗ

ប្រុញ ៖ អឺចឹងអរគុណច្រើនអ្នកមីង ៗ

«ចប់»